**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងសុខាភិបាល**

# សេចក្តីជូនព័ត៌មានរបស់ក្រសួងសុខាភិបាល
# ស្តីពី
# ការរកឃើញ ០២ ករណីថ្មីទៀត ជាអ្នកទេសចរជនជាតិបារាំង និង ០៣ ករណីថ្មី ជាបុរសជនជាតិខ្មែរ វិជ្ជមានវីរុសកូវីដ១៩ ហើយមានអ្នកជាសះស្បើយចំនួន ០៤នាក់

ក្រសួងសុខាភិបាល សូមគោរពជម្រាបជូនសាធារណជនទាំងអស់ ឲ្យបានជ្រាបថា លទ្ធផលពីវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា នាថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ វេលាម៉ោង១៨:០០នាទី បានបង្ហាញលទ្ធផលវិភាគវត្ថុសំណាក វិជ្ជមានវីរុសកូវីដ១៩ ចំនួន ០៥ករណីថ្មីទៀត មានដូចខាងក្រោម៖

**១. នៅខេត្តព្រះសីហនុ៖ ០២ ករណី ជាជនជាតិបារាំង**

- បុរសអាយុ៦៨ឆ្នាំ និងស្ត្រីអាយុ៦០ឆ្នាំ មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងសណ្ឋាគារមួយក្នុងក្រុងព្រះសីហនុ។ ពួកគាត់ស្ថិតនៅក្នុងចំណោមក្រុមទេសចរបារាំងដែលរកឃើញមានវីរុសកូវីដ១៩ក្នុងពេលថ្មីៗនេះ។

**២. នៅរាជធានីភ្នំពេញ៖ ០១ ករណី ជាជនជាតិខ្មែរ វិជ្ជមានវីរុសកូវីដ១៩ និងបុរសចំនួន ០៣នាក់បានជាសះស្បើយ**

- បុរសអាយុ ២៧ឆ្នាំ មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមណ្ឌលសុខភាពចាក់អង្រែក្រោម។ ស្ត្រីជាដៃគូរបស់គាត់ មានលទ្ធផល អវិជ្ជមានវីរុសកូវីដ១៩។
- បុរសចំនួន ០៣ នាក់ (អាយុ ៧១ឆ្នាំ ៣៨ឆ្នាំ និង៣៣ឆ្នាំ) ដែលបានសម្រាកព្យាបាលនៅមណ្ឌលសុខភាពចាក់អង្រែក្រោម បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានចំនួន ០២លើក។

**៣. នៅខេត្តកណ្តាល៖ ០១ ករណី ជាជនជាតិខ្មែរ**

- បុរសអាយុ ៥៩ឆ្នាំ មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តកណ្តាល។ គាត់ជាអ្នកឆ្លងបន្តពីបុរសអាយុ ៦០ឆ្នាំ ដែលបានទៅប្រទេសម៉ាឡេស៊ីចូលរួមពិធីសាសនានៅទីនោះ។

**៤. នៅខេត្តសៀមរាប៖ ០១ ករណី ជាជនជាតិខ្មែរ**

- បុរសអាយុ ៣៧ឆ្នាំ មានតេស្តវិជ្ជមានវីរុសកូវីដ១៩ ដែលត្រូវបានដាក់ឲ្យនៅព្យាបាលក្នុងមន្ទីរពេទ្យខេត្តសៀមរាបរួចហើយ។ បុរសរូបនេះ ជាអ្នកបើកបរអោយក្រុមអ្នកទេសចរបារាំងដែលបានរកឃើញថាមានវីរុសកូវីដ១៩នៅខេត្តព្រះសីហនុក្នុងពេលថ្មីៗនេះ។

**៥. នៅខេត្តបាត់ដំបង**

ក្រុមការងារមន្ទីរសុខាភិបាលខេត្តបាត់ដំបង បានរកឃើញបុគ្គលចំនួន ០៦នាក់ អវិជ្ជមានវីរុសកូវីដ១៩ និងបុគ្គលចំនួន ០៤នាក់ទៀត ដែលកំពុងរង់ចាំលទ្ធផលវិភាគ។ ពួកគាត់ទាំង ១០នាក់ ជាអ្នកប៉ះ



ទីស្តីការក្រសួងសុខាភិបាល ផ្លូវលេខ ៨០ វិថីសម្តេចប៉ែន នុត (២៨៩) ភ្នំពេញ ទូរស័ព្ទ-ទូរសារ: (៨៥៥-២៣) ៨៨៥ ៩៧០ / ៨៨៤ ៩០៩

ពាល់ផ្ទាល់ជាមួយក្រុមទេសចរជនជាតិបារាំងដែលមានវីរុសកូវីដ១៩រកឃើញនៅខេត្តព្រះសីហនុក្នុងពេលថ្មីៗនេះ។ ដោយឡែក ក្រុមការងារក៏បានរកឃើញព្រះសង្ឃ ០១អង្គ ដែលបានជួបផ្ទាល់ជាមួយក្រុមទេសចរបារាំង ហើយបច្ចុប្បន្ន ព្រះតេជគុណ បាននិមន្តមកគង់នៅខេត្តកំពង់ឆ្នាំង នៅវត្តមួយ ហើយក្រុមការងារមន្ទីរសុខាភិបាលកំពុងតាមដានផងដែរ។

**៦. នៅខេត្តត្បូងឃ្មុំ៖**

បុរសអាយុ ៥២ឆ្នាំ បានជាសះស្បើយ ដោយទទួលបានលទ្ធផលតេស្តអវិជ្ជមានចំនួន ០២លើក។

**៧. សរុបករណីវិជ្ជមានវីរុសកូវីដ១៩ នៅទូទាំងប្រទេស៖**

ត្រឹមម៉ោង១៩:៣០ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០ ករណីវិជ្ជមានវីរុសកូវីដ១៩ សរុបទាំងអស់មានចំនួន ៩៦នាក់ (ស្រី ២៥នាក់ ប្រុស ៧១នាក់) ក្នុងនោះមានចំនួន ១០នាក់ ដែលបានជាសះស្បើយ គិតពីខែមករា ដល់បច្ចុប្បន្ននេះ។

ក្រុមការងាររបស់ក្រសួងសុខាភិបាល កំពុងតែធ្វើកិច្ចការស្រាវជ្រាវករណីថ្មីជាបន្តទៀត ហើយនឹងបន្តជម្រាបជូនដល់បងប្អូនសាធារណជន ប្រសិនបើមានរកឃើញករណីវិជ្ជមានវីរុសកូវីដ១៩ ថ្មីណាផ្សេងទៀត។

ក្រសួងសុខាភិបាលសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជាទីបំផុត ជូនដល់ថ្នាក់ដឹកនាំ មន្ត្រី-បុគ្គលិកសុខាភិបាល និងក្រុមគ្រូពេទ្យទាំងអស់នៅទូទាំងប្រទេស ស្ថាប័ន និងអាជ្ញាធរពាក់ព័ន្ធទាំងអស់ទាំងនៅថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ អង្គការសុខភាពពិភពលោក មជ្ឈមណ្ឌលប្រយុទ្ធនឹងជំងឺឆ្លងសហរដ្ឋអាមេរិក និងវិទ្យាស្ថានប៉ាស្ទ័រកម្ពុជា ដែលបានខិតខំបំពេញភារកិច្ចបានល្អប្រសើរបំផុត ក្នុងការជួយពិនិត្យសុខភាព និងស្រាវជ្រាវរកករណីកូវីដ១៩ ព្រមទាំងអ្នកប៉ះពាល់ទាំងអស់កន្លងមក រួមទាំងការដាក់វិធានការនានា ដើម្បីទប់ស្កាត់ការចម្លងវីរុសកូវីដ១៩ នៅក្នុងប្រទេសកម្ពុជា។

ក្រសួងសុខាភិបាល បន្តជូនដំណឹងដល់សាធារណជនអំពីការវិវត្តន៍នៃបញ្ហាសុខភាព តាមទំព័រហ្វេស ប៊ុក និងគេហទំព័ររបស់ក្រសួង www.cdcmoh.gov.kh ដែលគេហទំព័រនេះមានសម្ភារៈអប់រំសុខភាពដែលអាចទាញយកមកប្រើប្រាស់បាន។ សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងមកទូរស័ព្ទទាន់ហេតុការណ៍ ក្រសួងសុខាភិបាល លេខ ១១៥ ដោយឥតគិតថ្លៃ ឬទំនាក់ទំនងក្រសួងសុខាភិបាល តាមលេខទូរស័ព្ទ៖ ០១២ ៨២៥ ៤២៤ ឬ ០១២ ៤៨៨ ៩៨១ ឬ ០១២ ៨៣៦ ៨៦៨ ។

ថ្ងៃពុធ ០២កើត ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស. ២៥៦៣

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០២០

ចំនួនករណីវិជ្ជមានកូវីដ ១៩ ថ្មីដែលបានរកឃើញប្រចាំថ្ងៃ




ប្រភពៈ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០២០

### ភាគរយនៃករណីវិជ្ជមានកូវីដ ១៩ តាមជនជាតិ
### ក្នុងចំណោម ៩៦ ករណីដែលបានរកឃើញ




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

## គិតដល់ថ្ងៃ ២៥ ខែមីនា ឆ្នាំ២០២០

## ករណីវិជ្ជមានកូវីដ ១៩ តាមភេទ
## ក្នុងចំណោម ៩៦ ករណី




ប្រភព៖ ក្រសួងសុខាភិបាល

# ស្ថានភាពនៃជំងឺកូវីដ ១៩ នៅកម្ពុជា

(ចំនួនករណីវិជ្ជមានកូវីដ១៩ សរុប ៩៦ករណី គិតដល់ថ្ងៃទី២៥ ខែមីនា ឆ្នាំ២០២០)




ប្រភព៖ ក្រសួងសុខាភិបាល

សំគាល់៖ សុំកែតម្រូវតួលេខនៅខេត្តកែបមក ៤នាក់វិញដោយមាន
ការវាយកំហុសច្រឡំពីថ្ងៃទី ២៤ ខែមីនា ឆ្នាំ២០២០